# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងពិធីប្រកាសពានរង្វាន់ និង ចែកវិញ្ញាបនបត្រផលិតភាព ស៥ ឆ្នាំ២០១៣




នៅរសៀលថ្ងៃទី២៥ ខែ មេសា ឆ្នាំ២០១៤ នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានរៀបចំ ពិធីប្រកាសពានរង្វាន់ និងចែកវិញ្ញាបនបត្រផលិតភាព ស៥ ឆ្នាំ២០១៣ ដែលរៀបចំដោយមជ្ឈមណ្ឌលផលិតភាពជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោមអធិបតីភាពឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួង និងតំណាងសហគ្រិនក្នុងស្រុកជាច្រើនរូបទៀត ។



តាមរបាយការណ៍របស់លោក **ហេង អៀង** ប្រធានមជ្ឈមណ្ឌលផលិតភាពជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបញ្ជាក់ថា:កាលពីដើមឆ្នាំ២០១៣ មជ្ឈមណ្ឌលផលិតភាពជាតិ នៃអតីត:ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បច្ចុប្បន្នក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលជាកន្លែងប្រមូលគំនិត និងប្រឹក្សាយោបល់អំពីឧបករណ៍លើក កំពស់ផលិតភាព បានលើកគម្រោងស្នើសុំទៅអគ្គនាយកដ្ឋានឧស្សាហកម្ម និងការរៀបចំកម្មវិធីប្រកួតពានរង្វាន់ផលិតភាពស៥ សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម នៅក្នុងប្រទេសកម្ពុជា ។ ដោយយល់ឃើញថា: វិធីសាស្ត្រ ដែលមានដើមកំណើត ពីប្រទេសជប៉ុនមួយនេះ ហើយផ្តើមចេញពីអក្សរ សទាំង៥ រួមមាន:សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដា និង ស្ថិតស្ថេរ គឺជាវិធីសាស្ត្រដ៏មានអត្ថប្រយោជន៍ដ៏សំខាន់ និងជាមូលដ្ឋានគ្រឹះដំបូង ឆ្ពោះទៅចាប់យកស្តង់ដាឈានមុខមួយចំនួនទៀតរួមមាន: GMP,ISO9001:2008,HACC និង ISO22000:2005 ជាដើម ។

នៅក្នុងគម្រោងនេះ ត្រូវបានបែងចែកសកម្មភាពផ្សេងៗ ដូចជា:យុទ្ធនាការផ្សព្វផ្សាយ ការចុះទៅធ្វើសវនកម្ម និងកម្មវិធីប្រកួតប្រជែងផ្ទៃក្នុងជាដើម ដើម្បីស្វែងរកអ្នកមានចំនាត់ថ្នាក់ល្អ ក្នុងការទទួលយកជ័យលាភីរបស់កម្មវិធីនេះ និងមានសិក្ខាសាលារៀបចំចំនួនពីរលើក: សិក្ខាសាលាទី១: គឺជាសិក្ខសាលាផ្សព្វផ្សាយពីគោលបំណង និងការដាក់ពាក្យប្រកួតប្រជែង ក្នុងការជ្រើសរើសក្រុមហ៊ុនយ៉ាងតិចចំនួន១០ សម្រាប់ធ្វើការប្រកួតប្រជែង និងសិក្ខាសាលាទី២ :គឺជាការសម្រិតសម្រាំងយកក្រុមហ៊ុន០៥ ដើម្បីប្រកួតប្រជែង និងជាចុងក្រោយយកបីក្រុមហ៊ុន ដែលមានពិន្ទុច្រើនជាងគេ ដើម្បីទទួលយកជ័យលាភី និងវិញ្ញាបនបត្រសម្រាប់អ្នកដែលមិនទទួលបានចំណាត់ថ្នាក់ល្អ ។ ជាលទ្ធផល គឺសហគ្រាសផលិតកម្មចំនួន ១០ នៅរាជធានីភ្នំពេញ ត្រូវបានជ្រើសរើស នៅក្នុងការប្រកួតប្រជែងពានរង្វាន់ផលិតភាពស៥ រួមមាន: **ទី១**-សហគ្រាសផលិតនំស្រួយលីលី **ទី២**-សហគ្រាសទឹកពិសារ អេរ៉ូតិច **ទី៣**-ហាងផលិតនំអប្សរា **ទី៤**- សហគ្រាស គីស៊ីវឆេង ប្រូតេអ៊ីនហ្វូត **ទី៥**-សហគ្រាស ខេស៊ីផលិតផលអាហារ **ទី៦**-សេងហួរ ហ្វាហ្វាហ្វូត **ទី៧**-ហាងនំ Asia Bakery Confectioning **ទី៨**-សហគ្រាសផលិតសាច់ប៉ាតេមានជ័យ **ទី៩**-សិប្បកម្ម ហ្គួយ ហ៊ុយឆេង និងទី១០-Direct Queen Company ដែលក្រុមហ៊ុន និងសហគ្រាសទាំង១០ខាងលើនេះ គឺភាគច្រើន សុទ្ធតែមានបទពិសោធន៍ នៅក្នុងការអនុវត្តវិធីសារស្តនេះ ដោយអ្នកប្រឹក្សាយោបល់របស់មន្ត្រីមជ្ឈមណ្ឌលផលិតភាពជាតិ តាមរយ:សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ ក្រោមជំនួយបច្ចេកទេសរបស់អង្គការផលិតភាពអាស៊ី (APO) និងអង្គការ JICA ជប៉ុន ក្រោមគម្រោងសាកល្បង ការគាំទ្រការធ្វើអាជីវកម្ម សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម កាលពីឆ្នាំ ២០១០-២០១១ កន្លងមកនេះ ។

បន្ទាប់ពី លោក **អ៊ុំ សេរីវុទ្ធ** ប្រធានការិយាល័យជម្រុញផលិតភាព បានធ្វើបទបង្ហាញសង្ខេបស្តីពី សកម្មភាពទូទៅរបស់គម្រោង ដូចជា:ការជ្រើសរើសក្រុមហ៊ុន និងលក្ខខ័ណ្ឌវិនិច្ឆ័យ សម្រាប់ដាក់ពិន្ទុ នៃការចុះធ្វើសវនកម្ម និងលក្ខន្តិក:នៃការវាយតម្លៃដោយគណ:កម្មការ ស៥ សម្រាប់ការប្រកួតប្រជែង ពានរង្វាន់ស៥ រួចមក តំណាងក្រុមហ៊ុន សហគ្រាសឆ្នើមទាំង៣ ដែលទទួលបានពានរង្វាន់ផលិតភាពស៥ បានឡើងមានប្រសាសន៍ចាប់អារម្មណ៍ ដោយបានសម្តែងនូវទឹកចិត្តរីករាយ និងថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលផលិតភាពជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការចុះជួយបណ្តុះបណ្តាល ផ្សព្វផ្សាយពីគោលការណ៍ ស៥ សម្រាប់ភាពជោគជ័យរបស់ក្រុមហ៊ុន-សហគ្រាសមកដល់បច្ចុប្បន្ន ព្រមទាំងបង្ហាញពីសារ:សំខាន់ និងការប្តេជ្ញាចិត្តក្នុងការអនុវត្តគោលការណ៍នេះឱ្យបានខ្ជាប់ខ្ជួន ដើម្បីភាពជោគជ័យក្នុងរបរអាជីវកម្ម

របស់ខ្លួនផង និង ជាពិសេសនឹងមានលទ្ធភាពអាច ឆ្ពោះទៅចាប់យកស្តង់ដាឈានមុខមួយចំនួនទៀតដូចជាៈ GMP, ISO9001:2008,HACC និង ISO22000:2005 ជាដើម ។








ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្តែងនូវទឹកចិត្តសោមនស្សរីករាយ ក្នុងពិធីប្រគល់ពានរង្វាន់ និងចែកវិញ្ញាបនបត្រ ស៥ ដ៏មានសារៈសំខាន់នេះ ដែលជាឆ្នាំដំបូងនៃការផ្តល់ពានរង្វាន់ ស៥ ដល់ក្រុមហ៊ុន ឆ្នើមចំនួន៣ ក្នុងចំណោមក្រុមហ៊ុន សហគ្រាស ចំនួន១០ ក្នុងរាជធានីភ្នំពេញ គឺៈសហគ្រាស លីលី ផលិតនំស្រួយ- ក្រុមហ៊ុនផលិតទឹកពិសារ អេរ៉ូតិច និងក្រុមហ៊ុនផលិតនំ ABC Backery ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថាៈសហគ្រាសខ្នាតតូច និងមធ្យម ជាផ្នែកស្នូលនៃសេដ្ឋកិច្ច ។ ពួកគេមានអត្រារហូតជិត ៩៩% នៃចំនួនសហគ្រាស និងឧស្សាហកម្មទូទាំងប្រទេសកម្ពុជា ហើយរួមចំណែកបង្កើត បង្កើតចំណូលដល់ប្រជាពលរដ្ឋ និងទ្រទ្រង់ខឿនសេដ្ឋកិច្ច ដែលស្មើមួយភាគធំនៃផលិតផលក្នុងស្រុកសរុប (GDP) ហេតុនេះការកសាងសមត្ថភាព និងលើកតម្លៃសហគ្រាសធុនតូច និងមធ្យមមិនអាចមើលរំលងនោះទេ ។ សហគ្រាររបស់យើងកំពុងប្រឈមនូវបរិយាកាសប្រកួតប្រជែងជាច្រើន ដែលស្របជាមួយគ្នានេះ សមត្ថភាពរបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ភាគច្រើននៅមានកំរិត គឺទី១ៈខ្វះវិធីសាស្ត្រគ្រប់គ្រងតាមបែបស្តង់ដាអន្តរជាតិ ទី២ៈពុំទាន់ប្រើប្រាស់អស់សមត្ថភាព និងធនធានដែលមានស្រាប់ និងទី៣ៈផលិតភាព និងប្រសិទ្ធិភាពនៃការផលិតនៅពុំទាន់ល្អប្រសើរ ។ កត្តាទាំងនេះបណ្តាលឱ្យខាតបង់ ក្នុងរូបភាពជាច្រើមន ដូចជាៈ ថ្លៃដើមផលិតកម្មកើនឡើង ដោយមិនដឹងមូលហេតុ រយៈពេលផលិតក្នុងមួយឯកតាកើនឡើងខុសប្រក្រតី សុវត្ថិភាពការងារពុំទាន់គ្រប់គ្រាន់ល្អ ទឹកចិត្តបុគ្គលិកកម្មករថមថយ គុណភាពផលិតផលពុំមានស្ថិរភាព ដែលនាំឱ្យទំនុកចិត្តអតិថិជនប្រែប្រួល និងចុងក្រោយសមត្ថភាពប្រកួតប្រជែងរបស់សហគ្រាស ពុំអាចរក្សាភាពរឹងមាំក្នុងទីផ្សារបានយូរ ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ គេហកិច្ចល្អ0៥ យ៉ាង ដេលហៅថាៈ ស៥ អាចជួយទប់ស្កាត់ លុបបំបាត់ រឺកាត់បន្ថយភាពឈឺក្បាលទាំងស្រុង ដល់សហគ្រាសធុនតូច និងមធ្យមបាន ។ តើវាអាចជួយបានដូចម្តេច? ហេតុអ្វីបានជាវិធីសាស្ត្រ ស៥ នេះត្រូវបានប្រើជាទូទៅក្នុងក្រុមហ៊ុនខ្នាតតូច ដល់ខ្នាតយក្ស សូម្បី តែនៅក្នុងក្រុមហ៊ុនផលិតរថយន្តតូយ៉ូតា

របស់ប្រទេសជប៉ុន ក៏អនុវត្តវិធីសាស្ត្រស៥ នេះដែរ ។ គេហកិច្ច ០៥ យ៉ាង រឺស៥ជាវិធីសាស្ត្រសាមញ្ញ ងាយស្រួលអនុវត្ត ចំណាយធនធានតិចបំផុត វាចាប់ផ្តើមពីពាក្យសទីមួយគឺៈ **សម្រិតសម្រាំង ៖** សម្រាំងយកតែវត្ថុចាំបាច់សម្រាប់ប្រើក្នុងផលិតកម្ម ហើយដកចេញនូវអ្វីដែលមិនចាំបាច់ឱ្យអស់ចេញ សទី២ៈសណ្តាប់ធ្នាប់ៈគឺរៀបវត្ថុចាបាច់ទាំងអស់ឱ្យមានសណ្តាប់ធ្នាប់ តាមលំដាប់ តាមលេខរៀង តាមធ្នើ តាមថ្នាក់ តាមពណ៌ តាមប្រភេទ តាមទំហំ តាមទីកន្លែង ដែលនាំឱ្យងាយស្រួលយក ពេលណាត្រូវការ សទី៣ៈសម្អាត ដែលមានន័យថាៈសម្អាតគ្រប់ទីកន្លែង ដោយមិនលើកលែងទាំងក្នុងនិងក្រៅក្រុមហ៊ុន ពិដាន ឥដ្ឋ ជញ្ជាំង គ្រឿងបរិក្ខាផលិតកម្ម ដើម្បីធានាភាពស្អាត ភ្លឺរលោង គ្មានធូលី គ្មានស្នាមប្រឡាក់ សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ពុំអាចរក្សាបានទេ បើគ្មាន សទី៤ គឺ ស្តង់ដា ៖ ដែលមានន័យថាៈ សទាំងបី ខាងដើម ត្រូវអនុវត្តជាប្រចាំ មានកាលវិភាគអនុវត្ត មានសេចក្តីណែនាំអំពីរបៀបអនុវត្ត ស ទាំងបី ដល់បុគ្គលិក-កម្មករ ដែលនាំឱ្យអ្នកទាំងអស់អាចយល់បាន និងអនុវត្តតាមបាន និងសទី៥ៈ គឺស្ថិតស្ថេរ ដែលមានន័យថាៈប្រែក្លាយការងារសម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ឱ្យទៅជាទម្លាប់ធ្វើការ នៅក្នុងផ្នត់គំនិតបុគ្គលិក-កម្មករ ។ ពេលក្លាយជាទម្លាប់ រួមផ្សំនិងការលើកទឹកចិត្តរបស់ក្រុមហ៊ុន វានឹងជួយទ្រទ្រង់វិធីសាស្ត្រនេះ ឱ្យស្ថិតនៅបានយូរ ។ ឧទាហរណ៍ បុគ្គលិក-កម្មករជប៉ុនមានទម្លាប់ សម្អាត ៥នាទីមុនម៉ោងធ្វើការ និងក្រោយពេលចប់ម៉ោងធ្វើការ ដែលនេះជាការស្ម័គ្រចិត្តរបស់ពួកគេ ដោយគ្មានរំពឹងតម្លៃបន្ថែម ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈគោលការណ៍ស៥ គឺដូចជា វិជ្ជាមេផ្ទះ ដែលយើងទាំងអស់គ្នាត្រូវប្រកាន់ខ្ជាប់ជាប្រចាំ ហើយក្នុងក៏រិតប្រកួតប្រជែងថ្នាក់តំបន់ ឯកឧត្តម ស្នើឱ្យម្ចាស់សហគ្រិន និងក្រុមហ៊ុនទាំងអស់សម្រេចផលិតភាព ក៏ដូចជាគុណភាព និងសោភ័ណ្ឌភាព នៃផលិតផលរបស់ខ្លួន ជាពិសេសអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ផលិតភាពស៥ សម្រាប់ទាញឧត្តមភាពប្រកួតប្រជែង ដែលសហគមន៍សេដ្ឋកិច្ចអាស៊ាន នឹងលេចចេញជារូបរៀងឡើងនៅឆ្នាំ២០១៥ ខាងមុខនេះ ។ ជាការលើកទឹកចិត្ត ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់ថាៈក្រៅពីក្រុមហ៊ុនទាំងបី ដែលទទួលពានរង្វាន់ឆ្នើម គឺក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ចាប់ពីលេខ ៤ ដល់លេខ ០៧ គឺមានសិទ្ធិអាចប្រើប្រាស់ស្លាកសញ្ញាស៥ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើផលិតផលរបស់ខ្លួន ។ ចំណែកក្រុមហ៊ុន ដែលជាប់ចំនាត់ថ្នាក់ពីលេខ ០៨ ដល់លេខ ១០ ត្រូវខិតខំកែលម្អរសង្វាក់ផលិតកម្ម និងការគ្រប់គ្រងរបស់ខ្លួន ដើម្បីទទួលបានចំណាត់ថ្នាក់ប្រសើរជាង មុន ។

បន្ទាប់មក ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអញ្ជើញប្រគល់ពានមួយ និងវិញ្ញាបនបត្របញ្ជាក់មួយ ដល់ក្រុមហ៊ុន ដែលជាប់ចំណាត់ថ្នាក់ពីលេខ១ ដល់លេខ ៣ និង ប្រគល់វិញ្ញាបនបត្រមួយ ដល់ក្រុមហ៊ុន ដែលជាប់ចំណាត់ថ្នាក់ពីលេខ ៤ ដល់លេខ ១០ ផងដែរ ។


ពិធីចែកពានរង្វាន់ផលិតភាព ស៥ សំរាប់ឆ្នាំ២០១៣
ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម